# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ការផ្អាកសវនាការ

## ឌី សុជាតា

តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម កំពុងបន្តកិច្ចការរបស់ខ្លួននៅក្នុងសំណុំរឿង០០២ ដែលមានជនជាប់ចោទវ័យជរាបីរូបគឺ នួន ជា ខៀវ សំផន និងអៀង សារី ។ ដើម្បីពន្លឿននីតិវិធីរបស់ខ្លួនក្នុងការស្វែងរកនូវយុត្តិធម៌ជូនជនរងគ្រោះទាន់ពេលវេលា ក៏ដូចជាគោរពដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះមួយប្រកបដោយយុត្តិធម៌ តុលាការនេះបាននិរកមធ្យោបាយមួយចំនួនដូចជា ការបំបែកសំណុំរឿង០០២ ។ ស្របពេលសំណុំរឿងកំពុងដំណើរការ ជនជាប់ចោទ អៀង សារី មានជម្ងឺ មិនអាចមានលទ្ធភាពចូលរួមសវនាការ ហើយបានស្នើសុំឲ្យអង្គជំនុំជម្រះផ្អាកនីតិវិធីសវនាការជាញឹកញាប់ ។ សំណើរបស់ជនជាប់ចោទ អៀង សារី ក្នុងការសុំផ្អាកសវនាការ តែងតែទទួលបានការអនុវត្ត ដោយសារអង្គជំនុំជម្រះផ្អែកលើការគោរពសិទ្ធិជនជាប់ចោទ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង និងសន្ធិសញ្ញាអន្តរជាតិ ការពារសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ ។

ក្រោយពីការបំបែកសំណុំរឿងឲ្យទៅជាផ្នែកតូចៗ ដោយសារតែជម្ងឺរបស់ជនជាប់ចោទសំណុំរឿង០០២ បាននិវត្តខ្លួនមកដល់វគ្គទីពីរនៃដំណាក់កាលទីមួយ ដែលអង្គជំនុំជម្រះបានស្តាប់ចម្លើយរបស់អ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនរូបកន្លងមក ។ ក្នុងដំណើរការជំនុំជម្រះប្រចាំថ្ងៃការចូលរួមរបស់ជនជាប់ចោទទាំងបីរូប គឺមានភាពបត់បែនទៅតាមស្ថានភាពសុខភាពរបស់ជនជាប់ចោទម្នាក់ៗ ។ ជាទូទៅ ខៀវ សំផន ដែលជាអតីតប្រធានប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិតេយ្យ តែងតែស្ថិតនៅក្នុងបន្ទប់សវនាការ ចូលរួមដោយផ្ទាល់នៅក្នុងនីតិវិធីជាប្រចាំ ។ ចំណែកជនជាប់ចោទពីររូបទៀតគឺ នួន ជា និង អៀង សារី មានជម្ងឺ និងតែងតែស្នើសុំលះបង់សិទ្ធិចូលរួមដោយផ្ទាល់នៅក្នុងសវនាការ ដោយសម្រាកនៅបន្ទប់ខាងក្រោម ។ រៀងរាល់ពេលសៀលក្នុងថ្ងៃសវនាការ ជនជាប់ចោទ នួន ជា អតីតប្រធានសភាប្រជាជននៃរបបខ្មែរក្រហម តែងតែស្នើសុំទៅតាមដានដំណើរការសវនាការនៅក្នុងបន្ទប់រង់ចាំខាងក្រោម ដែលមានបំពាក់ទៅដោយបច្ចេកវិជ្ជាសោតទស្សន៍ ដើម្បីឲ្យជនជាប់ចោទអាចតាមដានសវនាការ ដែលកំពុងប្រព្រឹត្តនិងអាចមានលទ្ធភាពក្នុងការទំនាក់ទំនងមកមេធាវីរបស់ខ្លួន ។ ជនជាប់ចោទ នួន ជា បានស្នើសុំធ្វើបែបនេះ ដោយសំអាងលើមូលហេតុថា ខ្លួនឈឺចង្កេះមិនអាចអង្គុយនៅក្នុងបន្ទប់សវនាការបានមួយថ្ងៃពេញ ។

កាលពីចុងខែឧសភា ឆ្នាំ២០១២ កន្លងទៅអង្គជំនុំជម្រះបានផ្អាកដំណើរការនីតិវិធីរបស់ខ្លួនម្តងរួចទៅហើយ ដោយសារជនជាប់ចោទ អៀង សារី មានជម្ងឺបេះដូង សរសៃឈាម និងរលាកទងសួត ដែលបណ្តាលឲ្យក្អកជាប់ និងពិបាកដកដង្ហើម ។ រហូតមកដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ

២០១២នេះ តាមរយៈមេធាវីអន្តរជាតិរបស់ខ្លួន ជនជាប់ចោទ អៀង សារី បានស្នើសុំផ្អាកនីតិវិធី ដោយសារវិលមុខ និងអស់កម្លាំង មិនអាចតាមដាន ដំណើរការនីតិវិធីសវនាការបាន។

យោងតាមវិធាន៨១ នៃវិធានផ្ទៃក្នុង បានតម្រូវឲ្យមានវត្តមានរបស់ជនជាប់ចោទនៅក្នុងការចូលរួមដំណើរការសវនាការជំនុំជម្រះ។ វិធាននេះបានផ្តល់សិទ្ធដល់ជនជាប់ចោទ ក្នុងករណីដែលជនជាប់ចោទមានជម្ងឺ អាចស្នើសុំលះបង់សិទ្ធចូលរួមសវនាការបាន ដោយអនុញ្ញាតឲ្យមេធាវីរបស់ខ្លួនប្រើប្រាស់សិទ្ធការពារក្តីជំនួសប្រសិនបើខ្លួនមានបំណង។ អៀង សារី មិនបានលះបង់សិទ្ធក្នុងការចូលរួមតាមដានដំណើរការនីតិវិធីនោះទេ។ នៅក្នុងការស្នើសុំផ្អាកសវនាការចំនួនពីរលើកនេះ អៀង សារី បានអះអាងថា ដោយសារសាក្សីដែលអង្គតុលាការកំពុងស្តាប់ចម្លើយ គឺបានផ្តល់សក្ខីកម្មជាច្រើនពាក់ព័ន្ធនឹងខ្លួន ដូច្នេះ អៀង សារី មិនមានបំណងលះបង់សិទ្ធក្នុងការចូលរួមតាមដានសវនាការនេះទេ។ ជាលទ្ធផល បន្ទាប់ពីការស្តាប់យោបល់របស់លោកវេជ្ជបណ្ឌិត អង្គជំនុំជម្រះបានយល់ព្រមទៅតាមសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ដោយសម្រេចផ្អាកនីតិវិធីរបស់ខ្លួនម្តងទៀត ដើម្បីរង់ចាំការព្យាបាលដោយវេជ្ជបណ្ឌិត។

ខណៈពេលដែលអង្គជំនុំជម្រះកំពុងតែបំពេញកិច្ចការងាររបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពនោះ ប្រជាជន និងសិស្សានុសិស្សមួយចំនួន ដែលទៅស្តាប់ការកាត់ទោសមេដឹកនាំខ្មែរក្រហម មានការខកចិត្តចំពោះការផ្អាកសវនាការជំនុំជម្រះជនជាប់ចោទទាំងអស់ ដោយសារតែសំណើសុំផ្អាកសវនាការរបស់ អៀង សារី។ អ្នកទាំងនោះយល់ថាការពន្យាពេលសវនាការអាចធ្វើឲ្យប៉ះពាល់ដល់ការទន្ទឹងរង់ចាំរបស់ជនរងគ្រោះ ចំពោះការកាត់ក្តីមេដឹកនាំនៃរបបខ្មែរក្រហមនេះ។ ក្តីព្រួយបារម្ភជាចំបងនោះ គឺថាជនជាប់ចោទ ដែលមានវ័យជរាណាស់ទៅហើយ អាចទទួលមរណៈភាពមុនពេលការកាត់ទោសត្រូវបានបញ្ចប់។

បើទោះបីជាមានការរិះគន់មួយចំនួនទៅលើស្ថាប័នតុលាការដែលមានការចូលរួមពីភាគីអន្តរជាតិនេះខ្លះក៏ដោយ ក៏អង្គជំនុំជម្រះនៅតែបន្តកិច្ចការរបស់ខ្លួន ដើម្បីឆ្ពោះទៅរកការជំនុំជម្រះមួយ ដែលរំពឹងថា ប្រកបដោយយុត្តិធម៌ និងសុក្រិត្យភាព។ ការផ្អាកដំណើរការសវនាការ ដោយទុកពេលសម្រាប់ព្យាបាលដល់ជនជាប់ចោទបៀបនេះ គឺជាការលើកស្ទួយនូវការគោរពសិទ្ធរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះមួយត្រឹមត្រូវប្រកបដោយយុត្តិធម៌ និងមានសារៈសំខាន់ណាស់ក្នុងការជៀសវាងនូវសវនាការកំបាំងមុខ។ ការគោរពសិទ្ធជនជាប់ចោទនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ក៏ជាសកម្មភាពដែលលើកកំពស់ដល់ការគោរពសិទ្ធជនជាប់ចោទទាំងឡាយ ដែលកំពុងទទួលការជំនុំជម្រះនៅក្នុងសមត្ថកិច្ចនៃតុលាការក្នុងប្រទេសកម្ពុជា។ គម្រូនៃតុលាការអន្តរជាតូបនីយកម្មមួយនេះ អាចដឹកនាំសង្គមជាតិកម្ពុជា ឆ្ពោះទៅការគោរពសិទ្ធ និងនីតិរដ្ឋនាពេលអនាគត។